**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ០៥ សរណន**

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២

## ១- សេចក្តីផ្តើម

១-មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា ៣ ដំណាក់កាលគឺៈ (១)-**ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, (២)-**ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង (៣)-**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ ផ្អែកលើក្របខ័ណ្ឌគោលនយោបាយនេះ, រាជរដ្ឋាភិបាលក៏បានដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ដើម្បីឱ្យគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ធ្វើការពន្យល់ និងផ្តល់អំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូល និងបង្ហាញអំពីតម្រូវការចំណាយរយៈពេល ៣ ឆ្នាំ សម្រាប់អនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ដែលនឹងរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**"។ សម្រាប់ដំណាក់កាលទី ២ នេះ, រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខ័ណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ ២០២២ របស់គ្រប់ក្រសួង-ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។ ដូច្នេះ សារាចរណែនាំនេះ ដាក់ចេញនូវក្របខ័ណ្ឌនិងវិធានការប្រមូលចំណូល, ការកំណត់អាទិភាពចំណាយតាមវិស័យ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ, អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង-ស្ថាប័ន នាឆ្នាំកន្លងមក។

២-ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំមួយផ្សេងទៀត ដែលត្រូវដាក់ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស /រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១, ដោយឈរលើមូលដ្ឋាន និងគោលការណ៍

ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកាដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការប្រមូលចំណូល, ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធិភាពនៃការអនុវត្តចំណាយ ទាំងកម្រិតបច្ចេកទេស និងកម្រិតប្រតិបត្តិការ ក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និងរក្សាអតិរេកសាច់ប្រាក់។

៣-ក្នុងឆ្នាំ ២០២០ ពិភពលោកទាំងមូលបានជួបប្រទះនឹងវិបត្តិសុខភាពសាធារណៈជាសកល ដែលបណ្តាលមកពីការផ្ទុះរីករាលដាលយ៉ាងឆាប់រហ័សនៃជំងឺកូវីដ-១៩ រហូតឈានទៅដល់ការបិទប្រទេស, ការបិទទីក្រុង, និងការរឹតត្បិតការធ្វើដំណើរ សំដៅទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ហើយជាលទ្ធផលសេដ្ឋកិច្ចសកលបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ក្នុងអត្រា -៣,៥%។ ក្នុងកាលៈទេសៈបែបនេះ កម្ពុជាក៏មិនអាចគេចផុតបានដែរ ជាក់ស្តែងកំណើនសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះក្នុងអត្រា -៣,១% និងបានជះឥទ្ធិពលអវិជ្ជមានដល់ស្ថានភាពហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២០ ដែលឱនភាពថវិកាសរុបឆ្នាំ ២០២០ បានធ្លាក់ដល់ប្រមាណ -៨,៤៩% នៃ ផ.ស.ស. ។ ក្នុងកិច្ចខិតខំទប់ទល់នឹងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានធ្វើវិចារណកម្មនូវមុខសញ្ញាចំណាយដែលពុំសូវចាំបាច់ និងលែងចាំបាច់មួយចំនួន ដើម្បីបង្វែរថវិកាទៅដោះស្រាយតម្រូវការបន្ទាន់និងចាំបាច់ភ្លាមៗ ដោយផ្តោតលើអាទិភាពចំនួន ៤ រួមមាន៖ (១)-ការប្រយុទ្ធប្រឆាំង នឹងជំងឺកូវីដ-១៩, (២)-ការរក្សាលំនឹងជីវភាពប្រជាជន ពិសេសប្រជាជនក្រីក្រ និងអ្នកបាត់បង់ការងារ, (៣)-ការរក្សាលំនឹងធុរកិច្ច និងអាជីវកម្ម ពិសេសជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និង (៤)-ការរក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម។

៤-ថវិកាឆ្នាំ ២០២១ ត្រូវបានរៀបចំឡើងតាម**គោលនយោបាយវិត្តារកម្មថវិកា** ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ **ចំណាយចាំបាច់ទាំងឡាយសំដៅបន្តទប់ទល់នឹងការរាតត្បាត និងកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងដោះស្រាយផលប៉ះពាល់ធ្ងន់ធ្ងរពីជំនន់ទឹកភ្លៀងដែលកើតឡើងនៅឆ្នាំ ២០២០។** ប៉ុន្តែការផ្ទុះរីករាលដាលនូវជំងឺកូវីដ-១៩ ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ ២០២១ ដែលឈានទៅអនុវត្តវិធានការបិទខ្ទប់នៅទីតាំងភូមិសាស្ត្រមួយចំនួនក្នុងទ្រង់ទ្រាយធំ ជាពិសេស រាជធានីភ្នំពេញ ក្រុងតាខ្មៅ នៃខេត្តកណ្តាល និងក្រុងព្រះសីហនុ នៃខេត្តព្រះសីហនុ កំពុងធ្វើឱ្យមានផលប៉ះពាល់ដល់ក្របខ័ណ្ឌច្បាប់ថវិកាឆ្នាំ ២០២១ ជាទូទៅ និងតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវធ្វើវិចារណកម្មចំណាយថវិកាឡើងវិញ ក្នុងបុព្វហេតុសន្សំធនធានដើម្បីបង្វែរថវិកាមកដោះស្រាយបញ្ហាជាអាទិភាពនាពេលបច្ចុប្បន្ន ទប់ទល់ផលប៉ះពាល់អវិជ្ជមានមកលើសង្គម-សេដ្ឋកិច្ច។ លើសពីនេះទៀត, សេដ្ឋកិច្ចកម្ពុជាបន្តប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់ រួមមាន៖ ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ និងការបំប្លែងខ្លួនថ្មីនៃវីរុសកូរ៉ូណា (new variants) ព្រមទាំងការអូសបន្លាយនៃការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំក្នុងស្រុក, ការថមថយនៃលំហូរទុនវិនិយោគពីបរទេស, ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចសកលទាបជាងការរំពឹងទុក ដែលបង្កឡើងដោយសារភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា ជាដើម។

៥-ក្នុងបរិបទនៃការគិតគូរស្តារកំណើនសេដ្ឋកិច្ច តាមរយៈការសម្របខ្លួនបានទៅនឹងប្រក្រតីភាពថ្មី (new normal) ព្រមជាមួយនឹងភាពធូរស្រាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលត្រូវបានរំពឹងទុកបន្ទាប់ពីការចាក់វ៉ាក់សាំងត្រូវបានអនុវត្តយ៉ាងទូលំទូលាយពេញផ្ទៃប្រទេស, **ឆ្នាំ ២០២២ ដែលជាឆ្នាំទី ៤ នៃរាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា** ទាមទារឱ្យរាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តមោះមុតក្នុងការដាក់ចេញ

និងអនុវត្តយ៉ាងម៉ឺងម៉ាត់ នូវវិធានការអន្តរាគមន៍សមស្របឱ្យបានទាន់ពេលវេលា ដោយបោះជំហានលើគន្លងអភិវឌ្ឍន៍ថ្មី ផ្សារភ្ជាប់នឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល និងបន្តគ្រប់គ្រងផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ និងការកែទម្រង់ជារចនាសម្ព័ន្ធដើម្បីឈានឆ្ពោះទៅសម្រេចបាននូវភាពធន់នឹងវិបត្តិ ដោយផ្តោតសំខាន់លើ៖ (១)-ការពង្រឹងសមត្ថភាពស្ថាប័នប្រកបដោយឆន្ទៈនយោបាយខ្ពស់ក្នុងទិសដៅជំរុញការកែទម្រង់ជារចនាសម្ព័ន្ធ និងកសាងប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ, (២)-ការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចដែលតូចចង្អៀត និងបង្កើនភាពប្រកួតប្រជែង ដោយការធ្វើបរិវត្តកម្មឌីជីថល, ការគាំទ្រនិងផ្តល់ការលើកទឹកចិត្តដល់អាជីវកម្មក្នុងស្រុក, ការបង្កបរិយាកាសងាយស្រួលដល់ការធ្វើធុរកិច្ច, ការកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម, ការបន្តតម្រង់ទិសធនធានឱ្យកាន់តែចំគោលដៅអភិវឌ្ឍន៍នៃវិស័យជំរុញកំណើនជាអាទិភាព និង (៣)-ការកសាងប្រព័ន្ធគាំពារសង្គមរឹងមាំ និងប្រព័ន្ធសុខាភិបាលប្រកបដោយគុណភាព និងមានភាពឆ្លើយតបខ្ពស់។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ដូចខាងក្រោម៖

## ២- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២២

### ២.១- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២២

៦-ក្នុងឆ្នាំ ២០២០ កន្លងមកនេះ កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានក្នុងអត្រា -៣,១% ដែលកំណើននេះ ដោយសារការធ្លាក់ចុះយ៉ាងគំហុកនៃវិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម ខណៈវិស័យកសិកម្មនៅរក្សាបានកំណើនវិជ្ជមាន។ ការធ្លាក់ចុះនេះបានធ្វើឱ្យ ផ.ស.ស. សម្រាប់មនុស្សម្នាក់បានត្រឹម ១ ៦៥៣ ដុល្លារអាមេរិក។ ទន្ទឹមនេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំស្ថិតក្នុងរង្វង់ ២,៩% និងអត្រាប្តូរប្រាក់មធ្យមគឺប្រមាណ ៤ ០៨០ រៀលក្នុងមួយដុល្លារអាមេរិក។

៧-ដោយឡែក ក្នុងឆ្នាំ ២០២១ នេះ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានកាលពីដើមឆ្នាំថានឹងមានកំណើន ៤ % ស្របពេលដែល ផ.ស.ស. តាមថ្លៃបច្ចុប្បន្ន ត្រូវបានប៉ាន់ស្មានស្មើនឹង ១១៦ ៧១១ ប៊ីលានរៀល ដោយផ្អែកលើសម្មតិកម្មសំខាន់នៃវិសាលភាព និងប្រសិទ្ធភាពការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ គួបផ្សំនឹងគោលនយោបាយគាំទ្រនានា ដែលជួយជំរុញសកម្មភាពផលិតកម្ម, តម្រូវការប្រើប្រាស់ និងការបង្កើនទំនុកចិត្តសម្រាប់ការវិនិយោគ ។ ទោះជាយ៉ាងនេះក្តី, ការបន្តរីករាលដាលនៃព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ ២០២១ បាននិងកំពុងតែដាក់សម្ពាធបន្ថែម និងកាន់តែធ្ងន់ធ្ងរលើសេដ្ឋកិច្ចកម្ពុជា ដែលនឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចឆ្នាំ ២០២១ អាចនឹងមិនសម្រេចបានតាមការរំពឹងទុកកាលពីដើមឆ្នាំ ព្រោះជាក់ស្តែង វិស័យដែលត្រូវបានរំពឹងថានឹងជួយជំរុញកំណើនឡើងវិញ បាននិងកំពុងទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដែលក្នុងនោះរួមមាន៖ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន, អនុវិស័យលក់ដុំ-រាយ, អនុវិស័យសំណង់ និងអចលនទ្រព្យ, អនុវិស័យកាត់ដេរ, អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងអនុវិស័យដឹកជញ្ជូនជាដើម។

៨-សម្រាប់ឆ្នាំ ២០២២, លើមូលដ្ឋាននៃការព្យាករពីដើមឆ្នាំ ២០២១ សេដ្ឋកិច្ចកម្ពុជាគ្រោងនឹងសម្រេចបានកំណើនក្នុងរង្វង់ ៥,៧% ស្របពេលដែល ផ.ស.ស. តាមថ្លៃបច្ចុប្បន្នឆ្នាំ ២០២២ ត្រូវបានព្យាករថាស្មើនឹង

១២៧ ០២៣ ប៊ីលានរៀល ដោយសារការបន្តងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងសកល ទាំងសកម្មភាពផលិតកម្ម, តម្រូវការ, ការវិនិយោគ និងវំហូរមនុស្ស ដែលនឹងជំរុញដល់ការងើបឡើងវិញនូវអនុវិស័យជំរុញកំណើនសំខាន់ៗ ដូចជា៖ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន, អនុវិស័យកាត់ដេរ, អនុវិស័យសំណង់ និងអចលនទ្រព្យ និងអនុវិស័យគាំទ្រផ្សេងទៀត។ តាមការរំពឹងទុកនេះ កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ ត្រូវបានគាំទ្រដោយ៖

- វិស័យកសិកម្មត្រូវបានព្យាករថានឹងមានកំណើន ក្នុងរង្វង់ ១,៣% ក្នុងឆ្នាំ ២០២១ និង ១,១% ក្នុងឆ្នាំ ២០២២ ដោយសារកំណើនល្អប្រសើរឡើងវិញនៃអនុវិស័យដំណាំ និងការបន្តកំណើនវិជ្ជមាននៃអនុវិស័យនេសាទ ខណៈអនុវិស័យចិញ្ចឹមសត្វត្រូវបានរំពឹងថាមានកំណើនថមថយត្រឡប់ទៅរកនិន្នាការធម្មតាវិញ បន្ទាប់ពីមានកំណើនខ្ពស់ក្នុងឆ្នាំ ២០២០។ អនុវិស័យដំណាំ ត្រូវបានព្យាករថាសម្រេចបានកំណើន ១,៦% ក្នុងឆ្នាំ ២០២១ និង ១,២% ក្នុងឆ្នាំ ២០២២ ដោយសារការកើនឡើងនៃផលិតកម្មដំណាំស្រូវ, កៅស៊ូ, ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម។ អនុវិស័យនេសាទ ត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រា ១,៥% ក្នុងឆ្នាំ ២០២១ និង ១,៤% ក្នុងឆ្នាំ ២០២២ ក្រោមការរំពឹងទុកនូវការកើនឡើងការវិនិយោគលើអនុវិស័យវារីវប្បកម្ម ដោយសារការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងៗ តាមរយៈការគាំទ្រផ្នែកហិរញ្ញប្បទានសម្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព ខណៈផលនេសាទទឹកសាបបន្តមានកំណើនទាបធៀបនឹងនិន្នាការធម្មតា ក្រោមការរំពឹងទុកកម្រិតទឹកទន្លេទាបដែលមិនអំណោយផលដល់ការបង្កកំណើតត្រី។ អនុវិស័យចិញ្ចឹមសត្វ ត្រូវបានព្យាករថានឹងមានកំណើនថមថយមកនិន្នាការធម្មតាវិញ ក្នុងរង្វង់ ០,៦% និង ០,៨% ក្នុងឆ្នាំ ២០២១ និងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវកំណើនថមថយមកវិញនៃផលិតកម្មជ្រូកបន្ទាប់ពីមានសម្ទុះខ្លាំងក្នុងឆ្នាំ ២០២០ ខណៈផលិតកម្មបក្សីនៅបន្តកំណើនល្អ។ *ទោះជាយ៉ាង-នេះក្តី, វិស័យកសិកម្មនៅបន្តជួបប្រទះបញ្ហាប្រឈមជារចនាសម្ព័ន្ធ រួមមាន កំណើនទាបនៃផលិតភាពដីនិងផលិតភាពពលកម្ម, ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ភាពទន់ខ្សោយនៃការធ្វើពាណិជ្ជូបនីយកម្ម និងពិពិធកម្មកសិកម្ម និងកង្វះការកែច្នៃផលិតផលកសិកម្មឱ្យអស់ពីសក្តានុពល ដើម្បីទាញយកតម្លៃបន្ថែម។*
- វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងមានកំណើនក្នុងអត្រា ៥,៩% ក្នុងឆ្នាំ ២០២១ និង ៨,២% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការងើបឡើងវិញជាបណ្តើរៗនៃសកម្មភាពផលិតកម្ម, តម្រូវការសកល និងវំហូរទុនវិនិយោគ។ អនុវិស័យកាត់ដេរ ត្រូវបានព្យាករថានឹងកើនឡើងវិញក្នុងអត្រាកំណើនទាប ៤,៦% ក្នុងឆ្នាំ ២០២១ និង ៦,០% ក្នុងឆ្នាំ ២០២២ ដោយសារការងើបឡើងវិញនូវតម្រូវការសកល បន្ទាប់ពីការយាយីដ៏ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីដ-១៩ ពិសេសមកលើប្រទេសដៃគូនាំចេញសំខាន់ៗរបស់កម្ពុជា រួមមាន៖ សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ អនុវិស័យសំណង់ ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើនទាបក្នុងរង្វង់ ២,៩% ក្នុងឆ្នាំ ២០២១ និង ៧,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការត្រឡប់មកវិញនៃវំហូរទុនវិនិយោគពីបរទេស និងការងើបឡើងវិញនូវតម្រូវការក្នុងស្រុក។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ដែលកំពុងបង្ហាញនូវសញ្ញានៃការធ្វើពិពិធកម្មទំនិញនាំចេញ ត្រូវបានព្យាករថានឹងបន្តមានកំណើនខ្ពស់ក្នុងអត្រា ១២,៥% ក្នុងឆ្នាំ ២០២១ និង ១២,៧% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការបន្តកើនឡើងសកម្មភាពផលិតកម្ម ដើម្បីបម្រើការប្រើប្រាស់ក្នុងស្រុក និងការនាំចេញផលិតផលកម្មន្តសាលមិនមែនកាត់ដេរ។ *ជារួម, វិស័យឧស្សាហកម្មកម្ពុជានៅមានសក្តានុពលខ្ពស់ក្នុងការរួមចំណែកក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ ដូចនេះ ទាមទារនូវ*

ការបន្តជំរុញធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ, ការជំរុញការធ្វើពិពិធកម្មទីផ្សារសម្រាប់ការនាំចេញ, ការពង្រឹងការតភ្ជាប់ និងការបណ្ដុះបណ្ដាលធនធានមនុស្ស ជាដើម សំដៅពង្រឹងភាពប្រកួតប្រជែង និងពន្លឿនពិពិធកម្មសេដ្ឋកិច្ច។

• វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រាកំណើន ៣,៤% ក្នុងឆ្នាំ ២០២១ និង ៥,១% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកភាពប្រសើរឡើងវិញយឺតនៃសកម្មភាពធ្វើដំណើរ និងលំហូរទុនវិនិយោគពីបរទេស ដែលនឹងជួយជំរុញដល់អនុវិស័យអចលនទ្រព្យ, សណ្ឋាគារនិងភោជនីយដ្ឋាន និងអនុវិស័យដែលគាំទ្រដល់សកម្មភាពទេសចរណ៍។ អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋានត្រូវបានព្យាករថានឹងងើបឡើងវិញបន្តិចពីមូលដ្ឋានទាបក្នុងឆ្នាំ ២០២០ ក្នុងអត្រា ០,៣% ក្នុងឆ្នាំ ២០២១ និង ៤,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការកើនឡើងភ្ញៀវទេសចរក្នុងស្រុក ដែលអាចប៉ះប៉ូវមួយផ្នែកដល់ការបន្តធ្លាក់ចុះនៃភ្ញៀវទេសចរអន្តរជាតិ និងការកើនឡើងក្នុងកម្រិតទាបនៃចំនួនភ្ញៀវទេសចរអន្តរជាតិ បន្ទាប់ពីជំងឺកូវីដ-១៩ បានស្រាកស្រាន្ត។ *ជារួម, បន្ថែមលើផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃវិបត្តិកូវីដ-១៩ អនុវិស័យនេះ ក៏ប្រឈមនឹងបញ្ហាមួយចំនួន រួមមាន៖ ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័ន, សមត្ថភាពស្ថាប័ន និងការធ្វើពិពិធកម្មគោលដៅ, ផលិតផល និងសេវាទេសចរណ៍ ព្រមទាំងការបាត់បង់តម្លៃបន្ថែមសេដ្ឋកិច្ចដោយសារអវត្តមាននៃឧស្សាហកម្ម និងសេវាកម្មគាំទ្រ នៅតែជាប្រការចាំបាច់ និងបន្ទាន់ដែលត្រូវពង្រឹង និងពង្រីក សំដៅធានាចីរភាពកំណើននៃវិស័យនេះ ក្នុងការបន្តតួនាទីជាចន្ទល់មួយសំខាន់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។* អនុវិស័យលក់ដុំ-រាយ ត្រូវបានព្យាករថានឹងកើនឡើងវិញ ក្នុងអត្រា ៣,២% ក្នុងឆ្នាំ ២០២១ និង ៤,៦% ក្នុងឆ្នាំ ២០២២ ដោយសារការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ និងតម្រូវការប្រើប្រាស់ក្នុងស្រុក ស្របនឹងនិន្នាការកំណើននៃអនុវិស័យផ្សេងៗក្នុងសេដ្ឋកិច្ចជាតិ។ *ទោះជាយ៉ាងនេះក្តី, ការបន្តអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ នៅតែជាហានិភ័យដល់អនុវិស័យនេះ ដែលអាចបង្កឱ្យមានការធ្លាក់ចុះប្រាក់ចំណូលរបស់ប្រជាជន និងតម្រូវការប្រើប្រាស់ក្នុងស្រុក តម្រូវឱ្យមានការបន្តតាមដាន ក៏ដូចជាប្រយុទ្ធប្រឆាំង និងទប់ស្កាត់ការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងដាក់ចេញនូវវិធានការដើម្បីក្សាលំនឹងសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។* អនុវិស័យអចលនទ្រព្យ ត្រូវបានព្យាករថានឹងងើបឡើងវិញក្នុងអត្រា ២,៧% ក្នុងឆ្នាំ ២០២១ និង ៤,៨% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកនូវការកើនឡើងយឺតនៃលំហូរទុនវិនិយោគពីបរទេស ខណៈការវិនិយោគ និងតម្រូវការក្នុងស្រុក លើអចលនទ្រព្យដែលមានថ្លៃទាប និងមធ្យមត្រូវបានរំពឹងថានឹងបន្តរក្សាកំណើនល្អប្រសើរ។ អនុវិស័យដឹកជញ្ជូននិងគមនាគមន៍ ត្រូវបានព្យាករថានឹងមានកំណើន ៤,៥% ក្នុងឆ្នាំ ២០២១ និង ៥,៩% ក្នុងឆ្នាំ ២០២២ ដោយសារការរំពឹងទុកការងើបឡើងវិញនៃអនុវិស័យគាំទ្រសំខាន់ៗ រួមមាន អនុវិស័យកាត់ដេរ, សំណង់ និងសណ្ឋាគារនិងភោជនីយដ្ឋាន និងការកើនឡើងខ្លាំងនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ *ទោះជាយ៉ាងនេះក្តី, អនុវិស័យនេះនៅបន្តប្រឈមនឹងបញ្ហាមួយចំនួន ដូចជា៖ ភាពទន់ខ្សោយនៃប្រព័ន្ធដឹកជញ្ជូន និងឡូជីស្ទីក ខណៈការរៀបចំផែនការមេគ្រប់ជ្រុងជ្រោយនៃវិស័យនេះមិនទាន់បានបញ្ចប់នៅឡើយ ដែលជាប្រការនេះគឺចាំបាច់ត្រូវមានការដាក់ចេញវិធានការគោលនយោបាយពាក់ព័ន្ធមួយចំនួនសម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះ សំដៅធានាចីរភាពកំណើននៃវិស័យនេះ ក្នុងការបន្តតួនាទីជាចន្ទល់មួយសំខាន់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ។*

• អត្រាអតិផរណានៅក្នុងឆ្នាំ ២០២១ និងឆ្នាំ ២០២២ ត្រូវបានព្យាករថានឹងកើនឡើងបន្តិច ប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងរង្វង់ ៣,១ និង ៣,០% រៀងគ្នា ដោយសារការកើនឡើងនៃថ្លៃដឹកជញ្ជូនក្រោមការរំពឹងទុកការងើបឡើងវិញនៃនិន្នាការថ្លៃប្រេងលើទីផ្សារអន្តរជាតិ បន្ទាប់ពីតម្រូវការ និងសកម្មភាពផលិតកម្មសកលមានការកើនឡើងវិញ ស្របពេលដែលអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ត្រូវបានរំពឹងថាស្ថិតក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិក ដោយសារអន្តរាគមន៍របស់**ធនាគារជាតិនៃកម្ពុជា** ក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ និងទំនុកចិត្តពីសាធារណជនលើការប្រើប្រាស់ប្រាក់រៀល។

• ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងកើនឡើងដល់ទំហំ ១៤,៧% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២១ ធៀបនឹង ៦,៦% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២០ ជាមួយនឹងការរំពឹងទុកនូវការកើនឡើងនៃការនាំចូល ដោយសារការងើបឡើងវិញនូវសកម្មភាពប្រើប្រាស់ក្នុងស្រុក និងសកម្មភាពសេដ្ឋកិច្ចជារួម។ ទោះយ៉ាងនេះក្តី, ក្នុងឆ្នាំ ២០២២ ឱនភាពគណនីចរន្តត្រូវបានរំពឹងថានឹងរួមតូចបន្តិចមកវិញ មកត្រឹមអត្រា ១២,៨% នៃ ផ.ស.ស. ដោយសារការរំពឹងទុកការកើនឡើងនៃការនាំចេញ និងនិន្នាការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ។ ជាមួយគ្នានេះ លំហូរទុនវិនិយោគបរទេសត្រូវបានព្យាករថានឹងកើនឡើងវិញដល់ ១២,០% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២១ និង ១២,៣% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២២ ស្របជាមួយការងើបឡើងវិញនូវទំនុកចិត្ត និងសកម្មភាពវិនិយោគសកល។ ជាលទ្ធផល ទុនបម្រុងអន្តរជាតិសរុប ត្រូវរំពឹងថានឹងបន្តកើនឡើងដល់ ២១ ៦១៧ លានដុល្លារអាមេរិក និង ២២ ១១៨ លានដុល្លារអាមេរិក ដែលធានាការនាំចូលបាន ១០,៩ ខែ ក្នុងឆ្នាំ ២០២១ និង ១០,១ ខែ ក្នុងឆ្នាំ ២០២២។

៩-ទោះជាយ៉ាងនេះក្តី, ដូចបានគូសបញ្ជាក់ខាងលើ, ភាពមិនប្រាកដប្រជាខ្ពស់នៃការបន្តរីករាលដាលនៃព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ អាចនឹងធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២១ មិនសម្រេចបានតាមការរំពឹងទុក ដែលជាយថាហេតុអាចនឹងបង្កផលប៉ះពាល់ជាអវិជ្ជមាន សម្រាប់ការរំពឹងទុកនៃការបន្តងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០២២។ ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបន្តតាមដាន និងឃ្លាំមើលការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចដោយម៉ត់ចត់ និងជាប់ជាប្រចាំ ជាពិសេស ត្រូវធ្វើការវាយតម្លៃកំណើនសេដ្ឋកិច្ចឆ្នាំ ២០២១ រួមជាមួយនឹងការព្យាករកំណើនសេដ្ឋកិច្ចឆ្នាំ ២០២២ ឱ្យកាន់តែមានភាពសុក្រិត និងឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែង នៅក្នុងបរិការណ៍នៃការវាយតម្លៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ២០២១ ដើម្បីជាមូលដ្ឋានសម្រាប់ការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង នាពេលខាងមុខ។

## ២.២- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២២

១០-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២២ ដែលត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ និង"**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤**" និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣** ពិសេសក្នុងក្របខ័ណ្ឌនៃការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ មានគោលបំណងសំខាន់ៗ ដូចតទៅ៖

• បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ;
• បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន;
• បន្តដាក់ចេញក្របខ័ណ្ឌចំណាយអន្តរាគមន៍សង្គម-សេដ្ឋកិច្ច សំដៅការពារអាយុជីវិត និងសុខភាព

របស់ប្រជាជន ព្រមទាំងធានារក្សាលំនឹងសេដ្ឋកិច្ច ជីវភាពរបស់ប្រជាពលរដ្ឋ និងដោះស្រាយផលប៉ះពាល់នានា ដែលនៅសេសសល់ពីវិបត្តិជំងឺកូវីដ-១៩;

- បន្តអនុវត្តគោលនយោបាយអាទិភាពលើផ្នែកគាំពារសង្គម និងបង្កើនគុណភាពសេវាសុខាភិបាលព្រមទាំងជំរុញការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គម ដើម្បីអាចឆ្លើយតបនឹងគ្រោះអាសន្នជាយថាហេតុ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ;
- ជំរុញការកែទម្រង់រចនាសម្ព័ន្ធចាំបាច់នានា;
- បន្តតម្រង់ទិសធនធានទៅអភិវឌ្ឍវិស័យអាទិភាព ក្នុងបរិការណ៍ក្រោយវិបត្តិជំងឺកូវីដ-១៩ ដូចជា វិស័យកសិកម្ម, វិស័យទេសចរណ៍, វិស័យឌីជីថល និងវិស័យកម្មន្តសាលថ្មីៗ ដើម្បីជំរុញការងើបឡើងនៃកំណើនសេដ្ឋកិច្ច និងពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច;
- បន្តគាំទ្រការអភិវឌ្ឍវិស័យឯកជន និងសហគ្រាសធុនតូចនិងមធ្យម តាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្តជាក់លាក់, ការបង្កភាពងាយស្រួលក្នុងការធ្វើធុរកិច្ចដើម្បីធ្វើឱ្យរស់រវើកឡើងវិញនូវសកម្មភាពអាជីវកម្មក្នុងស្រុក និងការបង្កលក្ខណៈងាយស្រួលក្នុងការទទួលបានកម្ចីការប្រាក់ទាប;
- បន្តលើកកម្ពស់វិនិយោគសាធារណៈលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធបៃតង និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, ការអភិវឌ្ឍប្រកបដោយចីរភាព និងការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់ ស្របតាមតម្រូវការទីផ្សារ និងប្រក្រតីភាពថ្មី;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ;
- បន្តគិតគូរដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទក្នុងកម្រិតសមស្រប ដោយផ្អែកលើសមិទ្ធកម្ម ឬគុណាធិបតេយ្យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ និង
- ធានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ ២០២២ និងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន ២០២២ ក្នុងនាមជាម្ចាស់ផ្ទះ។

១១-ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌថវិកាឆ្នាំ ២០២២ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ ទាំងផ្នែកចំណូល និងផ្នែកចំណាយសម្រាប់ឆ្នាំ ២០២២ ដូចខាងក្រោម៖

## ២.២.១- ក្របខ័ណ្ឌចំណូលថវិកាឆ្នាំ ២០២២

១២-គម្រោងចំណូលថវិកាឆ្នាំ ២០២២ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំណូលសរុបក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ ២០២២ គ្រោងសម្រេចឱ្យបាន ២១,៤៧% នៃ ផ.ស.ស. គឺកើនឡើង ៣,១០ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ២៧,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២១) ក្នុងនោះ៖

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ ២១,២៨% នៃ ផ.ស.ស. គឺកើនឡើង ៣,០៩ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ២៧,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។ **ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ត្រូវគ្រោងសម្រេចឱ្យបាន ៩,០៣% នៃ ផ.ស.ស. គឺកើនឡើង ០,៨៩ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ២០,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ** ត្រូវគ្រោងសម្រេចឱ្យបាន ៨,៣៥% នៃ ផ.ស.ស. គឺកើនឡើង ១,៤៧ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ៣២,៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១, និង**ចំណូលមិនមែនសារពើពន្ធ** ត្រូវគ្រោងសម្រេចឱ្យបាន ២,១៧% នៃ ផ.ស.ស. គឺថយចុះ ០,១០ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ៣,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។
- **ចំណូលមូលធនក្នុងប្រទេស** ត្រូវសម្រេចឱ្យបាន ០,១៩% នៃ ផ.ស.ស. គឺកើនឡើង ៩,៨% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១។
- ចំណែកឯ **ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន ៤,៥៨% នៃ ផ.ស.ស. គឺថយចុះ ០,១០ ពិន្ទុភាគរយ នៃ ផ.ស.ស. ឬកើនឡើង ៦,៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ហើយ**មូលនិធិទ្រទ្រង់ថវិកា**គ្រោងសម្រេចឱ្យបាន ០,៩៩% នៃ ផ.ស.ស.។

១៣-ដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឹងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ក្នុងផ្នែកគយនិងរដ្ឋាករ ផ្នែកពន្ធដារ និងផ្នែកមិនមែនសារពើពន្ធ។

### ក.១- ផ្នែកចំណូលពន្ធដារ

១៤-វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ រួមមាន៖

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្ត និងដាក់ចេញនូវវិធានការថ្មីៗចាំបាច់បន្ថែមទៀត ដល់វិស័យដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ សំដៅទ្រទ្រង់និងស្តារអាជីវកម្ម និងធុរកិច្ចឱ្យងើបឡើងវិញ;
- បន្តពិនិត្យ និងកែតម្រូវអត្រាពន្ធកាត់ទុកលើកម្ចីរបស់ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ គ្រប់ប្រភេទ ទាំងក្នុង និងក្រៅស្រុក ស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច និងវិបត្តិជំងឺកូវីដ-១៩;
- ពង្រីកវិសាលភាពនៃការប្រមូលចំណូលពន្ធពាក់ព័ន្ធនឹងអចលនទ្រព្យដោយ៖ (១)-ការពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, (២)-ការពង្រីកវិសាលភាពនៃការប្រមូលពន្ធលើអចលនទ្រព្យនៅទីប្រជុំជន, (៣)-ការពិនិត្យឡើងវិញការលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្សញាតិ, (៤)-ការពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា

តាមច្បាប់ជាធរមាន និង (៥)-បន្តរៀបចំយន្តការសម្រាប់ពង្រឹងការអនុវត្តតារាងឧបសម្ព័ន្ធតម្លៃអចលនទ្រព្យថ្មី សម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ និងពន្ធលើអចលនទ្រព្យ;

- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធក្នុងវិស័យកម្មន្តសាលផលិតភេសជ្ជៈ ជាពិសេសស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា;
- បន្តជំរុញការចុះបញ្ជីសហគ្រាស និងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធក្នុងការចុះបញ្ជីពន្ធដារ ដើម្បីបង្កើនមូលដ្ឋានអ្នកជាប់ពន្ធ;
- ពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យ ដោយផ្អែកលើការវិភាគ និងវាយតម្លៃផលប៉ះពាល់វដ្តធុរកិច្ច តាមរយៈការប្រមូល និងវិភាគទិន្នន័យព័ត៌មានអំពីហានិភ័យអនុលោមភាព និងកែសម្រួលឯកសារបច្ចុប្បន្នភាពនៃការវិភាគហានិភ័យទូទៅ;
- ពង្រឹងការចែករំលែកព័ត៌មាន និងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងអគ្គនាយកដ្ឋានចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឈានទៅបង្កើតមជ្ឈមណ្ឌលរក្សាទិន្នន័យរួម;
- រៀបចំផែនការសវនកម្មប្រចាំឆ្នាំ និងកាត់បន្ថយការធ្វើសវនកម្មជាន់គ្នា (សវនកម្មពេញលេញ និងសវនកម្មមានកម្រិត) ដើម្បីសម្រួលបន្ទុកដល់អ្នកជាប់ពន្ធ; និង
- ធ្វើបច្ចុប្បន្នភាព និងកែប្រែទៅជំនាន់ថ្មីលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើសមាហរណកម្មរដ្ឋបាលសារពើពន្ធឱ្យមានលក្ខណៈស្វ័យប្រវត្តិកម្មពេញលេញ និងប្រទាក់ក្រឡា។

### ក.២- ផ្នែកចំណូលគយ និងរដ្ឋាករ

១៥-វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ រួមមាន៖

- បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធគយ ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩;
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ;
- ពិនិត្យលទ្ធភាពកែសម្រួលមូលដ្ឋានគិតពន្ធ និងអត្រាអាករពិសេសលើទំនិញដែលមានលក្ខណៈប្រណិត, ប៉ះពាល់បរិស្ថាន និងសុខភាព ក្នុងករណីចាំបាច់;
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់-ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់អតិថិជន;
- កែសម្រួល និងដាក់ឱ្យអនុវត្តកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ តាមរយៈការផ្តល់ប្រព្រឹត្តកម្មពិសេសក្នុងការបំពេញបែបបទគយ និងបន្តពិនិត្យលទ្ធភាពបង្កើនចំនួនធុរជនល្អបំផុត;
- លើកកម្ពស់ការយល់ដឹងរបស់ធុរជនលើការងារបច្ចេកទេសគយ និងនីតិវិធីនៃការបំពេញបែបបទគយ តាមរយៈការផ្សព្វផ្សាយមគ្គុទ្ទេសក៍ និងវគ្គបណ្តុះបណ្តាលអំពីតម្លៃគិតពន្ធគយ, ចំណាត់ថ្នាក់ទំនិញ និងការអនុវត្តអត្រាពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ព្រមទាំងនីតិវិធីគយជាធរមាន;

- បន្តពង្រឹងយន្តការ និងពង្រីកបន្ថែមទៀតនូវវិសាលភាពនៃប្រតិបត្តិការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ;
- បន្តពង្រឹងប្រសិទ្ធភាពនៃការបង្ការ និងបង្ក្រាបបទល្មើសគយ តាមរយៈការចុះឃ្លាំមើលតំបន់ភូមិសាស្ត្រដែលមានហានិភ័យខ្ពស់, ការវិភាគព័ត៌មាននិងហានិភ័យ, និងការចែករំលែកព័ត៌មានសម្ងាត់ក្នុងកម្រិតទ្វេភាគី តំបន់ និងសកល;
- ពិនិត្យលទ្ធភាពរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគយគ្រប់គ្រងកណ្ណាគារផលិតកម្មមានដែនកំណត់ដែលធ្វើប្រតិបត្តិការកែច្នៃ ឬចម្រាញ់តេលសិលាផៅ ឬប៊ីទីមខនិជ; និង
- ជំរុញធ្វើទំនើបកម្ម និងធ្វើសន្ទានកម្មបច្ចេកវិទ្យាព័ត៌មានរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាឱ្យបានកាន់តែទូលាយ ដូចជាប្រព័ន្ធអាស៊ីគូដា, ប្រព័ន្ធបញ្ចរតែមួយជាតិ, ប្រព័ន្ធគ្រប់គ្រងហានិភ័យ, និង direct trader input ( DTI )។

## ក.៣- ផ្នែកចំណូលមិនមែនសារពើពន្ធ

១៦-វិធានការបន្តសម្រាប់អនុវត្តក្នុងឆ្នាំ ២០២២ រួមមានៈ

- ជំរុញការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រ ក្នុងន័យបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការកៀរគរចំណូលឱ្យអស់សក្តានុពល;
- ជំរុញការរៀបចំឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ;
- ជំរុញការរៀបចំក្របខ័ណ្ឌគតិយុត្តថ្មីក្នុងការគ្រប់គ្រងសហគ្រាសសាធារណៈ ឱ្យស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច;
- ជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ( SARMIS ) អនឡាញ នៅតាមក្រសួង-ស្ថាប័ន;
- បន្តអភិវឌ្ឍ និងបន្ថែមមុខងារដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដូចជា ការផ្តល់វិក្កយបត្រតាមអនឡាញ និងការបង់ចំណូលមិនមែនសារពើពន្ធតាមរយៈការទូទាត់បែបអេឡិចត្រូនិក( e-payment ), ការបន្តធ្វើបច្ចុប្បន្នភាព និងការដាក់បញ្ចូលកិច្ចសន្យាកិច្ចព្រមព្រៀង ឬអាជ្ញាបណ្ណ និងជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ;
- សិក្សា និងពិនិត្យលទ្ធភាពរៀបចំឡើងវិញការគ្រប់គ្រងជីផ្លូ និងនគរូបនីយកម្ម តាមរយៈការបែងចែកតំបន់ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង និងអភិវឌ្ឍស្របតាមសក្តានុពលតំបន់ និងផ្តល់ភាពងាយស្រួលក្នុងការផ្តល់សេវាសាធារណៈ;
- ផ្តល់ការគាំទ្រដល់ការអភិវឌ្ឍរមណីយដ្ឋានដែលមានសក្តានុពល ដើម្បីទាក់ទាញភ្ញៀវទេសចរ និងពង្រឹងការប្រមូលចំណូលឱ្យអស់លទ្ធភាព;
- បន្តដាក់ចេញវិធានការគាំទ្រ ឬអនុគ្រោះ ទៅតាមវិស័យដែលរងផលប៉ះទង្គិចពីជំងឺកូវីដ-១៩;
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល;

- ជំរុញ និងពង្រឹងការគ្រប់គ្រងការប្រមូលចំណូលពីធនធានរ៉ែ ដោយអនុវត្តយន្តការបង់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក, ជំរុញការអនុវត្តយន្តការអធិការកិច្ចចំពោះក្រុមហ៊ុន ឬអាជីវកម្ម, ពិនិត្យផ្ទាល់ដល់ទីតាំង ឬការដ្ឋានអាជីវកម្ម និងបង្កើនកិច្ចសហប្រតិបត្តិការរវាងក្រសួងទទួលបន្ទុក;
- ពិនិត្យឡើងវិញ និងកែសម្រួលថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច អនុលោមតាមគោលការណ៍ដែលអនុម័តដោយរាជរដ្ឋាភិបាល ដោយតម្រូវឱ្យបង់ថ្លៃឈ្នួលតាមទំហំសម្បទានដីសេដ្ឋកិច្ច ដែលទទួលបានជាជាងទំហំដីដែលបានធ្វើការឈូសឆាយ;
- រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងអាជ្ញាបណ្ណ និងចំណូលមិនមែនសារពើ-ពន្ធពីវិស័យរ៉ែ នៅថ្នាក់កណ្ដាល និងថ្នាក់ក្រោមជាតិ ឱ្យបានពេញលេញ ក្នុងគោលដៅពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល;
- ពិនិត្យ និងរៀបចំយន្តការស្តង់ដារក្នុងការគ្រប់គ្រង ការបែងចែក និងការប្រើប្រាស់រង្វាន់ពីសេវាសាធារណៈ ផ្អែកលើគោលការណ៍សមធម៌ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពប្រមូលចំណូល;
- បន្តជំរុញការស្នើសុំអាជ្ញាបណ្ណតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការបង់ចំណូលតាមប្រព័ន្ធធនាគារតាមរយៈការជំរុញបន្ថែមនៅពេលប្រតិបត្តិករមកបន្តអាជ្ញាបណ្ណ និងការចុះជំរុញតាមទីតាំងអាជីវកម្មផ្ទាល់។

### ២.២.២- ក្របខ័ណ្ឌចំណាយថវិកាឆ្នាំ ២០២២

១៧-ក្នុងការត្រៀមខ្លួនឱ្យបានរួចរាល់ឆ្លើយតបទៅនឹងហានិភ័យដែលអាចកើតឡើងជាយថាហេតុ និងអនុវត្តអន្តរាគមន៍ចាំបាច់នានា គម្រោងចំណាយថវិកាឆ្នាំ ២០២២ ត្រូវបានកំណត់ និងវិភាជតាមក្របខ័ណ្ឌរួមដូចខាងក្រោម៖

- **ចំណាយសរុបថវិការដ្ឋ** នៅឆ្នាំ ២០២២ នឹងកំណត់ក្នុងរង្វង់ ២៩,២៣% នៃ ផ.ស.ស. គឺកើនឡើង ១,៨០ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១៦,០% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ (ហៅកាត់ថា ច្បាប់ថវិកាឆ្នាំ ២០២១) ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៧,២០% នៃ ផ.ស.ស. និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩១% នៃ ផ.ស.ស. ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៨៨% នៃ ផ.ស.ស.។ **ចំណាយចរន្តថវិការដ្ឋ**ត្រូវកំណត់ក្នុងកម្រិត ១៦,៨១% នៃ ផ.ស.ស. គឺកើនឡើង ០,៧៤ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១៣,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ៖
  - **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៨,៤% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,១៤% នៃ ផ.ស.ស.។
  - **ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥១,៦% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៨,៦៧% នៃ ផ.ស.ស. ដោយផ្តោតលើតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ដំណើរការការងារ និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល ដូចជា ការការពារ និងទប់ទល់នឹងជំងឺកូវីដ-១៩, ការសម្របខ្លួនទៅនឹងបរិការណ៍ថ្មី, ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមជាដើម។

ទន្ទឹមនេះ សម្រាប់ឆ្នាំ ២០២២ ចំណាយមូលធនត្រូវបានគ្រោងប្រមាណ ១២,៤១% នៃ ផ.ស.ស. គឺកើនឡើង ១,០៥ ពិន្ទុភាគរយនៃ ផ.ស.ស. ឬកើនឡើង ១៨,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងគោលដៅស្តារ

និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ជាពិសេសជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមទាំងខាងផ្នែកសុខាភិបាល និងឌីជីថល។ **ចំណាយសរុបថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម៖

- **វិស័យរដ្ឋបាលទូទៅ៖** ត្រូវបានគ្រោងប្រមាណ ១,៧៩% នៃ ផ.ស.ស. សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការងារការទូត ពិសេសការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣, ការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការរៀបចំដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ ២០២២ និងការត្រៀមរៀបចំការបោះឆ្នោតសកលឆ្នាំ ២០២៣;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ត្រូវបានគ្រោងប្រមាណ ៤,១៨% នៃ ផ.ស.ស. ដោយបន្តផ្តោតលើការគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុជានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ;
- **វិស័យសង្គមកិច្ច៖** ត្រូវបានគ្រោងប្រមាណ ៧,០៤% នៃ ផ.ស.ស. សំដៅបន្តជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រនិងផែនការសកម្មភាពគន្លឹះ មានជាអាទិ៍៖ ការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពការទទួលបានសេវាសុខាភិបាល, ការពង្រឹងប្រព័ន្ធសុខភាពសាធារណៈដែលឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, ផែនការមេសម្រាប់ឆ្លើយតបទៅនឹងជំងឺកូវីដ-១៩, គោលនយោបាយជាតិគាំពារសង្គម ជាពិសេសកម្មវិធីជួយដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ, ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស និងគោលនយោបាយអាទិភាពផ្សេងទៀតលើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន;
- **វិស័យសេដ្ឋកិច្ច៖** ត្រូវបានគ្រោងប្រមាណ ៨,៥៩% នៃ ផ.ស.ស. ដោយផ្តោតលើការជំរុញ និងគាំទ្រការអនុវត្តគោលនយោបាយ, យុទ្ធសាស្ត្រនិងផែនការសកម្មភាពគន្លឹះ មានជាអាទិ៍៖ ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមឆ្នាំ ២០២១-២០២៦, ផែនការមេគ្រប់ជ្រុងជ្រោយស្តីពីប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទីក ២០២១-២០៣០, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ និងការបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា។ លើសពីនេះ គម្រោងចំណាយនៃវិស័យនេះ ក៏ផ្តោតលើជំរុញការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥ និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥;
- **ចំណាយផ្សេងៗ៖** ត្រូវបានគ្រោងក្នុងទំហំ ៥,៦១% នៃ ផ.ស.ស. ដើម្បីត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ, និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល

ដូចជា៖ ការត្រៀមបម្រុងសម្រាប់គ្រោះមហន្តរាយធម្មជាតិ កិច្ចការអធិបតេយ្យ និងស្បៀងបម្រុងជាដើម។

• **ចំណាយចរន្តថវិកាថ្នាក់ជាតិ** ត្រូវកំណត់ត្រឹម ១៥,១៩% នៃ ផ.ស.ស. កើនឡើង ១០,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ដែលក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៤៩,២៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៤៨% នៃ ផ.ស.ស. និង**ចំណាយក្រៅបន្ទុកបុគ្គលិក**មានសមាមាត្រស្មើនឹង ៥០,៧៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវជា ៧,៧១% នៃ ផ.ស.ស.។

• **ចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិ** ត្រូវកំណត់ត្រឹម ២,៥១% នៃ ផ.ស.ស. កើនឡើង ៣៤,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២១ ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក ០,៦៦% នៃ ផ.ស.ស. និងចំណាយក្រៅបន្ទុកបុគ្គលិក ១,៨៤% នៃ ផ.ស.ស. ដែលត្រូវប្រើប្រាស់ថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបមានប្រមាណ ១,៦៣% នៃ ផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិស្មើនឹង ០,៨៨% នៃ ផ.ស.ស.។

១៨-ក្នុងក្របខ័ណ្ឌនៃគោលដៅរក្សាលំនឹងសេដ្ឋកិច្ច និងទ្រទ្រង់កំណើនសេដ្ឋកិច្ចឡើងវិញ, រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការជាក់លាក់ និងមុតស្រួច ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០២២ ដូចខាងក្រោម៖

- បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ សំដៅធានាបាននូវលទ្ធភាពក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងដោះស្រាយបញ្ហាដែលនៅបន្តសេសសល់ពីវិបត្តិជំងឺកូវីដ-១៩;
- តម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ ប្រកបដោយបរិយាបន្ន និងចីរភាព តាមរយៈការផ្ដល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, និងការពង្រឹងប្រព័ន្ធគាំពារសង្គម, ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធសុខាភិបាល និងវិស័យហិរញ្ញវត្ថុ;
- កំណត់លក្ខខណ្ឌជ្រើសរើសក្របខ័ណ្ឌថ្មី សម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ដែលត្រូវសមាមាត្រនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ លើកលែងតែក្រសួងអាទិភាព ដែលទទួលបានគោលការណ៍ឯកភាពពីប្រមុខរាជរដ្ឋាភិបាល តាមសំណើរួមគ្នារបស់ក្រសួងមុខងារសាធារណៈ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាមី;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានា និងគោលនយោបាយអាទិភាព និងបន្តតម្រង់ទិសការប្រើប្រាស់ធនធានថវិកាជាតិ ដើម្បីជំរុញក្បាលម៉ាស៊ីនកំណើន;
- បន្តពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃសេវាសាធារណៈ;
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ;
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន និង នៅរដ្ឋបាលរាជធានី-ខេត្ត ព្រមជាមួយនឹងការពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីចាប់ផ្ដើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្ត

កិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្តល់ព័ត៌មានពីសមិទ្ធកម្ម;

- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដោយជំរុញការខ្ចីឱ្យអស់លទ្ធភាព ប៉ុន្តែសម្រាប់តែវិស័យអាទិភាព ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេសវិស័យបង្កើនផលិតភាពផលិតកម្ម ជំរុញការតភ្ជាប់ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង និង
- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់អនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧។

### ២.២.៣- ក្របខ័ណ្ឌតុល្យភាពថវិកាឆ្នាំ ២០២២

១៩-ជារួម ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្នែកចំណូល និងផ្នែកចំណាយខាងលើនឹងជួយសម្រេចបាននូវអតិរេកថវិកាចរន្តស្មើនឹងប្រមាណ ៤,៤៦% នៃ ផ.ស.ស. និងឱនភាពថវិកាសរុបក្នុងរង្វង់ ៧,៧៦% នៃ ផ.ស.ស. នៅក្នុងឆ្នាំ ២០២២។ ដូចនេះ រាជរដ្ឋាភិបាលនឹងត្រូវប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាលសរុបប្រមាណ ២,១៩% នៃ ផ.ស.ស. ដើម្បីមានលទ្ធភាពក្នុងការបន្តគាំទ្រគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, ការបន្តទប់ទល់នឹងផលប៉ះពាល់នៃការអូសបន្លាយវិបត្តិនៃជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ច-សង្គម, ការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា។

## ៣- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០២២

### ៣.១- ការគ្រោងចំណូលថវិកាឆ្នាំ ២០២២

២០-ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុន ដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖
    - លទ្ធផលដែលសម្រេចនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ (ឆ្នាំ ២០២១);
    - ចំណូលបន្ថែមដែលសង្ឃឹមថានឹងប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ;
    - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ;
    - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រានិងមូលដ្ឋានប្រមូលពន្ធ។

- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមគោលការណ៍ដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

## ៣.២- ការគ្រោងចំណាយថវិកាឆ្នាំ ២០២២

២១-ក្រសួង-ស្ថាប័ន **មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវបន្តយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រោងថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និងជាពិសេសត្រូវផ្តោតការយកចិត្តទុកដាក់លើការកំណត់លទ្ធផល ឬធាតុចេញ (Output) ដែលនឹងសម្រេចបាន។ ប្រការនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំថវិកា និងការពិភាក្សាចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការសិទ្ធិអំណាចនៃការអនុវត្តចំណាយផងដែរ។ លើសពីនេះ ក្រសួង-ស្ថាប័ន ក៏ត្រូវកែលម្អរចនាសម្ព័ន្ធកម្មវិធី និងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ ស៊ីសង្វាក់គ្នា និងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ ដើម្បីសម្រួលដល់ការអនុវត្តឱ្យកាន់តែរលូនល្អ ហើយឈានទៅសម្រេចបានលទ្ធផលល្អ និងមានការទទួលខុសត្រូវកាន់តែច្បាស់លាស់។ *សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២២-គ្រប់ក្រសួង-ស្ថាប័ន **មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ** (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំគម្រោងចំណាយដែលឆ្លុះបញ្ចាំងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា (ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវវិភាគឱ្យបានច្បាស់លាស់អំពីតម្រូវការចំណាយតាមចង្កោមសកម្មភាព អនុកម្មវិធី និងកម្មវិធី និងត្រូវភ្ជាប់មកជាមួយនូវឯកសារសម្រាប់គាំទ្រ រួមទាំងឯកសារអង្កេត ឬវិភាគតាមការចាំបាច់ ព្រមទាំងពន្យល់បញ្ជាក់អំពីភាពចាំបាច់នៃតម្រូវការចំណាយលើសកម្មភាពការងារនីមួយៗឱ្យបានគ្រប់ជ្រុងជ្រោយ ហើយឯកសារទាំងនេះ ក៏ជាកម្មវត្ថុសម្រាប់ការត្រួតពិនិត្យ ពិភាក្សា និងចរចាថវិកាផងដែរ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិក ដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ ២០២០ និងការប៉ាន់ស្មាននៃការអនុវត្តក្នុងឆ្នាំ ២០២១ និងដោយផ្អែកលើថ្លៃឯកតានៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២៣-ឈរលើមូលដ្ឋានតម្រូវការចំណាយ ដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ក្នុងកម្រិតនៃទំហំពិតានចំណាយគោលដែលបានផ្តល់ជូនគ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ), **ក្នុងការរៀបចំគម្រោងចំណាយថវិកាឆ្នាំ ២០២២ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារបានប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងចំណាយរបស់ខ្លួន ទៅតាម គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

**ក-ចំណាយបន្ទុកបុគ្គលិក(ជំពូក ៦៤)៖** នាយកដ្ឋានបុគ្គលិកដែលជាសេនាធិការរបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវសម្របសម្រួល និងគ្រោងចំណាយបន្ទុកបុគ្គលិកឱ្យបានសុក្រឹតតាមគោលការណ៍ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ពោលគឺត្រូវចៀសវាងការគ្រោងបៀវត្ស ឬបន្ទុកពាក់ព័ន្ធនឹងបុគ្គលិកនេះទុកចោល។ ក្នុងបរិការណ៍ដែលសេដ្ឋកិច្ចជាតិនៅបន្តរងផលប៉ះពាល់អវិជ្ជមានពីជំងឺកូវីដ-១៩ ជាពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ទាមទារឱ្យមានការវាយតម្លៃឡើងវិញនូវស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងចំណូលថវិកាជាតិ ឱ្យបានច្បាស់លាស់សិន ដើម្បីមានមូលដ្ឋានក្នុងការពិនិត្យលទ្ធភាពដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ។ ក្នុងន័យនេះ ការគ្រោងចំណាយបន្ទុកបុគ្គលិកសម្រាប់ឆ្នាំ ២០២២ ត្រូវអនុវត្តគោលការណ៍លម្អិត ដូចខាងក្រោម៖

- **ចំនួនក្របខ័ណ្ឌថ្មី** ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងចំនួនមន្ត្រីចូលនិវត្តន៍ និងត្រូវបញ្ជាក់អំពីគោលដៅនៃតម្រូវការ និងមុខងារនៃមន្ត្រីដែលត្រូវជ្រើសរើសបន្ថែមនេះ។ *ក្នុងករណីការជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីដែលមានចំនួនតិចជាងចំនួនមន្ត្រីចូលនិវត្តន៍នោះ ក្រសួង-ស្ថាប័នអាចស្នើសុំប្រើប្រាស់ថវិកានោះដើម្បីផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានគុណវុឌ្ឍិ និងសមត្ថភាពជំនាញខ្ពស់ និង/ឬ សម្រាប់បន្ថែមចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីជាប្រយោជន៍សម្រាប់អង្គភាពរបស់ខ្លួន ជាពិសេសសម្រាប់ការងារដែលមានចរិតយុទ្ធសាស្ត្រក្នុងការកែទម្រង់ និងសម្រេចគោលនយោបាយសំខាន់ៗរបស់ក្រសួង-ស្ថាប័ន;*
- ត្រូវគ្រោងទាំង**បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ** ដោយផ្អែកតាមចំនួនក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០២១ ព្រមទាំងតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងនៅក្នុងឆ្នាំ ២០២១;
- ត្រូវគ្រោង**ចំនួនមន្ត្រីជាប់កិច្ចសន្យា មិនឱ្យលើសពីចំនួន** ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២១ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវប្រើប្រាស់ប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ស្របតាមគោលការណ៍ដែលមានចែងក្នុងអនុក្រឹតលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា;
- ត្រូវគ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន;
- ចំពោះកញ្ចប់ថវិកាសម្រាប់ការបន្តកាត់បន្ថយគម្លាតប្រាក់សោធននិវត្តន៍រវាងអ្នកចូលនិវត្តចាស់ និងថ្មី នឹងត្រូវបានគ្រោងដោយឡែកនៅក្នុងចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

**ខ-ចំណាយក្រៅបន្ទុកបុគ្គលិក (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន)** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យ

អប់រំ) ត្រូវគ្រោងតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងគណនាតម្រូវការចំណាយនៃជំពូកនីមួយៗ ដូចខាងក្រោម៖

- កំណត់*ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់* ។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយជារៀងរាល់ឆ្នាំ ដែលរួមមាន៖ ការចំណាយសម្ភារផ្គត់ផ្គង់ និងថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជា សម្ភារការិយាល័យ ការបោះពុម្ព ការទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួង-ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ធនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំង**វិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬ អង្គភាពជំនាញដោយផ្ទាល់**។

- *កំណត់ចំណាយមិនប្រចាំ ដោយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាព នៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់*។ ចំណាយមិនជាប្រចាំ គឺជាចំណាយដែលមិនត្រូវការចំណាយជារៀងរាល់ឆ្នាំ រួមមានការចំណាយបំពាក់ឧបករណ៍ សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗ ដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ព កិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ ត្រូវកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ចំណាយប្រភេទនេះ សម្រាប់រយៈពេលមធ្យម និងមានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែង។

- **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ មិនទាន់ស្រាកស្រាន្តនៅឡើយ ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដែលបានបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរមកលើសុខភាពប្រជាពលរដ្ឋ សេដ្ឋកិច្ច និងសង្គម និងប៉ះពាល់មកលើចំណូលថវិកាជាតិឆ្នាំ ២០២១ និងអាចប៉ះពាល់ដល់ឆ្នាំ ២០២២, ដូចនេះ ជំនួសឱ្យពិតានចំណាយគោលដែលបានផ្តល់នៅក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២២-២០២៤, គ្រប់ក្រសួង-ស្ថាប័ន ត្រូវគ្រោងថវិកាយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃច្បាប់ថវិកាឆ្នាំ ២០២១ ព្រមទាំងត្រូវគិតគូរសន្សំសំចៃ និងកាត់បន្ថយចំណាយលើមុខសញ្ញាមិនទាន់ចាំបាច់ និងមិនសូវចាំបាច់មួយចំនួន ស្របតាមសារាចរណែនាំអំពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយថវិកាជាតិ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១។ រាល់ការគ្រោងចំណាយទាំងអស់ ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។

- **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ដូចគ្នានឹងក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាលដែរ, សម្រាប់ឆ្នាំ ២០២២ មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវគ្រោងថវិកាចំណាយយ៉ាងច្រើនបំផុតស្មើនឹង

កម្រិតអតិបរមានៃច្បាប់ថវិកាឆ្នាំ ២០២១។ **ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្ដល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តពាក់ព័ន្ធ ត្រូវផ្ដល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក **សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ** ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធន **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្ដល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀត ក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- ចំពោះការបន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការ ត្រូវគ្រោងចំណាយនៃកម្មវិធីនីមួយៗ ដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ ២០២០ កន្លងមក និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ ២០២១ នេះ និងដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយចៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃខ្ពស់ ពិសេសលើមុខសញ្ញាទិញឧបករណ៍ សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារិមប្រណិត ការបោះពុម្ពប្រណិត សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធិកអធម បេសកកម្មក្នុង និងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ដូចជាសេវាទូរគមនាគមន៍ អគ្គិសនី និងទឹក ជាដើម។ លើសពីនេះ ត្រូវលុបបំបាត់ការខ្ជះខ្ជាយចំណាយ ឬបំប៉ោងចំណាយលើការរៀបចំកិច្ចប្រជុំ សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ ការតាំងពិព័រណ៍។ ដោយឡែកកិច្ចប្រជុំពាក់ព័ន្ធនឹងអាស៊ាន គឺអនុញ្ញាតសម្រាប់តែកិច្ចប្រជុំដែលត្រូវវេន, ចំពោះកិច្ចប្រជុំដែលមិនចំវេន គឺត្រូវសុំគោលការណ៍អនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាលជាមុនសិន។ ចំពោះកិច្ចប្រជុំ ឬសិក្ខាសាលា ដែលគ្រោងក្នុងថវិកាត្រូវបង្ហាញពីភាពចាំបាច់ និងភាពសមរម្យនៃការរៀបចំទាំងក្នុងទំហំ និងតម្លៃ។

- ត្រូវពិនិត្យឡើងវិញ និងត្រូវកាត់ចេញនូវមុខចំណាយទាំងឡាយណាដែលមានតម្រូវការសម្រាប់តែអនុវត្តនៅក្នុងឆ្នាំ ២០២១ ហើយលែងត្រូវការនៅក្នុងឆ្នាំ ២០២២ ឬសកម្មភាពការងារដែលនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ ២០២១។ លើសពីនេះ ត្រូវកាត់ចេញនូវទំហំចំណាយនៃសកម្មភាពការងារមួយចំនួនដែលត្រូវបានវាយតម្លៃថាលែងមានសារៈសំខាន់ ដូចជា **សកម្មភាពចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្ម និងពិព័រណ៍ទេសចរមួយចំនួនដែលលែងមានភាពចាំបាច់។ ក្នុងន័យនេះ ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិនោះទេ លុះត្រាតែមានសកម្មភាពការងារចាំបាច់ថ្មី ឬគោលនយោបាយថ្មីដែលមានការសម្រេចច្បាស់លាស់ពីរាជរដ្ឋាភិបាលជាយថាហេតុ** ដែលត្រូវអនុវត្តនិងដែលត្រូវបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ និងមានយុត្តការណ៍អំពី

ភាពចាំបាច់ និង បន្ទាន់ មានការពន្យល់ និងផ្ដល់អំណះអំណាងយ៉ាងច្បាស់លាស់ និងត្រឹមត្រូវ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតច្បាស់លាស់ ទើបចាត់ទុកជាកម្មវត្ថុនៃការត្រួតពិនិត្យ និងពិភាក្សាអំពីលទ្ធភាពថវិកា។

- ចំពោះតម្រូវការចំណាយបន្ថែមលើសពីកម្រិតថវិកាអតិបរមានៃច្បាប់ថវិកាឆ្នាំ ២០២១ ចាំបាច់ត្រូវឆ្លងការចរចាកម្រិតថ្នាក់ដឹកនាំក្រសួង ឬក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងស្នើសុំការសម្រេច ឬស្នើសុំការសម្រេចឡើងវិញពីប្រមុខរាជរដ្ឋាភិបាល បន្ទាប់ពីមានឯកសារទស្សនាទាន យុត្តការណ៍ស្ដីពីគោលនយោបាយ និងកម្មវិធី ឬមុខសញ្ញាចំណាយ និងតម្លៃច្បាស់លាស់។ *សម្រាប់ក្រសួង-ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានភារកិច្ចប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំដាក់ចេញវិធានការជាក់ស្ដែងបន្ថែមសម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ព្រោះលទ្ធផល និងការបង្ហាញពីកិច្ចខិតខំក្នុងការប្រមូលចំណូល គឺជាកម្មវត្ថុនៃការរឹតត្បិត ឬការលើកទឹកចិត្តចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំ។*

- ត្រូវបង្កើនវិមជ្ឈការនៃការផ្ទេរចំណាយរដ្ឋបាលជាប្រចាំ និងសោហ៊ុយបេសកកម្មក្នុង និងក្រៅប្រទេសជាដើម ទៅឱ្យតាមអង្គភាពថវិកាឱ្យបានច្រើនក្នុងកម្រិតអតិបរមា។

- ដើម្បីអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាផែនការសកម្មភាពការងារទៅតាមកម្មវិធី និងលើកសំណើសុំថវិកាក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិការួមប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យ និងវិភាជថវិកាជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមលទ្ធភាពថវិកាជាក់ស្ដែង។

- **ក្រសួង-ស្ថាប័នត្រូវពិនិត្យលទ្ធភាពនៃការផ្ទេរធនធានថវិកាពីកម្មវិធីមួយទៅកម្មវិធីមួយទៀត ឬពីអង្គភាពថវិកាមួយទៅអង្គភាពថវិកាមួយទៀតនៅក្នុងក្រសួង-ស្ថាប័នតែមួយឱ្យអស់លទ្ធភាព** ព្រមជាមួយនឹងការថ្លឹងថ្លែងតុល្យភាពនៃការបែងចែកធនធាន និងសិទ្ធិអំណាចទៅតាម និងរវាងអង្គភាពថវិកានីមួយៗ ក្នុងក្របខ័ណ្ឌពិតានកញ្ចប់ថវិកាដែលបានកំណត់ និងត្រូវចៀសវាងការបំប៉ោងចំណាយ ដោយមូលហេតុនៃការអនុវត្តថវិកាកម្មវិធី។

- ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយនៅដំណាក់កាលរៀបចំ និងចរចាថវិកា **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ត្រូវបានអនុញ្ញាតឱ្យកាត់ចេញនូវថវិកាប្រភេទចំណាយមិនជាប្រចាំផ្ទៃក្នុងក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំង**រដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)។ ទំហំថវិកាដែលនៅសល់ក្នុងក្របខ័ណ្ឌពិតាននេះ អាចជាកម្មវត្ថុនៃការវិភាជសម្រាប់កែលម្អ ឬបង្កើនប្រសិទ្ធភាពនៃកម្មវិធីដែលមានស្រាប់ ឬសម្រាប់កម្មវិធីបម្រើឱ្យគោលនយោបាយថ្មី នៅក្នុងក្រសួង-ស្ថាប័នដដែល **ឬទៅក្រសួង-ស្ថាប័នមួយទៀត ឬពីមន្ទីរជំនាញមួយ ទៅមន្ទីរជំនាញមួយទៀតនៃក្រសួង-ស្ថាប័នតែមួយ ក៏ដូចជាពីមន្ទីរនៃរដ្ឋបាលខេត្តមួយ ទៅមន្ទីរនៃរដ្ឋបាលខេត្តមួយទៀត** ក្នុងក្របខ័ណ្ឌនៃវិស័យចំណាយតែមួយ។

**គ-ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ (ជំពូក ២១) និងចំណាយជួសជុល ស្ពាន និង ថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១)៖**

- ក្រសួងដែលទទួលបានចំណាយវិនិយោគជាទៀងទាត់ រួមមានៈ ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី ព្រមទាំងត្រូវរៀបចំបញ្ជីគម្រោងអាទិភាពប្រចាំឆ្នាំឱ្យបានទាន់ពេលវេលា ដើម្បីស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ឱ្យបានមុនការរៀបចំជាបញ្ជីគម្រោងសង្ខេបដែលប្រើប្រាស់ថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់)។ បញ្ជីគម្រោងសង្ខេបនេះ នឹងត្រូវវេចខ្ចប់ជាមួយនឹងចំណាយចរន្តនៅក្នុងសេចក្តីព្រាងច្បាប់ថវិកា។ ចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងមហាផ្ទៃ ព្រមទាំងក្រសួងសុខាភិបាល, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលត្រូវទទួលបានថវិកាជំពូក ២១ សម្រាប់គម្រោងវិនិយោគផ្ទាល់ ក៏ត្រូវចាប់ផ្តើមធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធីផងដែរ សម្រាប់ជាមូលដ្ឋានស្នើសុំការពិនិត្យ និងសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ ចំពោះការកំណត់អាទិភាព និងជ្រើសរើសគម្រោងដែលក្រសួងនីមួយៗបានស្នើឡើង គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង ដោយផ្អែកទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងគោលការណ៍កំណត់អាទិភាពគម្រោង ដែលមានចែងនៅក្នុងសារាចរនេះ។

- សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីទទួលបានថវិកាពីកញ្ចប់ថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល ត្រូវសិក្សា និងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងរៀបចំអាទិភាវូបនីយកម្មគម្រោង គោរពស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់របស់ប្រមុខរាជរដ្ឋាភិបាលទៅតាមលទ្ធភាពថវិកាប្រចាំឆ្នាំ។ គម្រោងវិនិយោគដែលអាចស្នើឡើងដើម្បីពិភាក្សា ត្រូវបំពេញតាមគោលការណ៍ និងលក្ខខណ្ឌតម្រូវដែលមានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ។

- ការគ្រោងចំណាយវិនិយោគសម្រាប់គម្រោង សាងសង់ ស្តារ ជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ប្រព័ន្ធធារាសាស្ត្រ ត្រូវផ្អែកលើគោលការណ៍កំណត់អាទិភាព ដូចខាងក្រោមៈ

- *<u>វិស័យផ្លូវថ្នល់</u>*
  - ✓ **អាទិភាពទី១៖** ជួសជុល ស្តារ និងថែទាំផ្លូវជាតិគ្រប់ប្រភេទ ដើម្បីធានាចីរភាពនៃប្រព័ន្ធគមនាគមន៍ និងចរាចរ និងទ្រទ្រង់ដង្ហើមសេដ្ឋកិច្ច។
  - ✓ **អាទិភាពទី២៖** ជួសជុល ស្តារ និងថែទាំផ្លូវខេត្ត និងផ្លូវជនបទសំខាន់ៗ ដែលមានលក្ខណៈជាឆ្អឹងខ្នងនៃប្រព័ន្ធគមនាគមន៍ ដែលបម្រើឱ្យការដឹកជញ្ជូន និងចរាចរ នៅកម្រិតមូលដ្ឋាន **កម្រិតតំបន់** និង កម្រិតជាតិ។
  - ✓ **អាទិភាពទី៣៖** គម្រោងថ្មីដែលមានការសម្រេចច្បាស់លាស់ពី**សម្តេចតេជោនាយករដ្ឋមន្ត្រី**។
  - ✓ **អាទិភាពទី៤៖** គម្រោងពហុឆ្នាំដែលត្រូវសាងសង់បញ្ចប់ ឬគម្រោងដែលមានចរិតពហុឆ្នាំ និងមានប្រសិទ្ធភាពខ្ពស់ រួមទាំងគម្រោងខូចខាតដែលបណ្តាលមកពីទឹកជំនន់។
  - ✓ **អាទិភាពទី៥៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។

- *វិស័យធារាសាស្ត្រ*
  - ✓ **អាទិភាពទី១៖** ជួសជុល ស្តារ និងថែទាំប្រព័ន្ធធារាសាស្ត្រគ្រប់ប្រភេទ ជាពិសេស ប្រព័ន្ធធារាសាស្ត្រដែលបានស្ថាបនារួចដោយថវិកាជាតិ ឬថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។
  - ✓ **អាទិភាពទី២៖** ស្ថាបនាប្រឡាយមេ និង/ឬប្រឡាយរងបន្ថែម ដើម្បីពង្រីកឱ្យអស់សក្តានុពលគម្រោងប្រព័ន្ធធារាសាស្ត្រធំៗដែលត្រូវបានស្ថាបនារួចដោយថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា។
  - ✓ **អាទិភាពទី៣៖** ស្ថាបនាបន្តប្រព័ន្ធធារាសាស្ត្រមិនទាន់អនុវត្តចប់ ដែលមានចរិតពហុឆ្នាំ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យក្លាយជាប្រព័ន្ធធារាសាស្ត្រមានសក្តានុពលពេញលេញ។ គម្រោងខូចខាត ដែលបណ្តាលមកពីទំកជំនន់ឬគ្រោះធម្មជាតិ។
  - ✓ **អាទិភាពទី៤៖** គម្រោងថ្មីដែលមានការសិក្សាច្បាស់លាស់ ហើយឃើញថាមានអាទិភាពខ្ពស់ ទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ រួមទាំងគម្រោងពាក់ព័ន្ធនឹងអធិបតេយ្យភាព និងអភិវឌ្ឍន៍តាមតំបន់ព្រំដែនផងដែរ។

- ក្រៅពីវិស័យផ្លូវថ្នល់ និងធារាសាស្ត្រ ការកំណត់អាទិភាពគម្រោងសម្រាប់វិស័យផ្សេងៗទៀត នឹងត្រូវផ្អែកលើអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេសក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០២២ ដែលបានកំណត់នៅផ្នែក **២.២** នៃសារាចរណែនាំនេះ។

**ឃ.ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍៖** ក្រសួង-ស្ថាប័នចំនួន ៩ ដែលនឹងទទួលបាននូវការវិភាជថវិកាជំពូក ២១ (គម្រោងវិនិយោគផ្ទាល់) និងថវិកាជំពូក ៦១ (ការងារ ជួសជុល និងថែទាំ) ព្រមទាំងក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០២២-២០២៤) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

២៤-ទន្ទឹមនេះ ចំណាយចរន្ត និងចំណាយវិនិយោគរបស់ក្រសួង-ស្ថាប័នមួយចំនួននៅថ្នាក់ជាតិ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការអភិវឌ្ឍនៅមូលដ្ឋាន ពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម នឹងត្រូវរក្សាមិនឱ្យមានកំណើន ឬអនុញ្ញាតឱ្យកើនតិចតួច ឬកាត់ចេញមួយចំនួននូវប្រភេទចំណាយថវិកាសម្រាប់អន្តរាគមន៍ដល់ថ្នាក់មូលដ្ឋានផ្ទាល់ ដោយត្រូវអនុវត្តតាមគម្រោងសាច់ប្រាក់ពលកម្មរបស់រាជរដ្ឋាភិបាល និងមួយផ្នែកទៀត គឺទុកឱ្យឃុំ-សង្កាត់ ធ្វើខ្លួនឯងវិញ ដូចជា៖ ការជីកស្រះ ការជីកអណ្តូង ការធ្វើបង្គន់អនាម័យ ការជីកប្រឡាយជើងក្អែបនៅតាមឃុំជាដើម ។ល។ តាមរយៈមូលនិធិអភិវឌ្ឍឃុំ-សង្កាត់ ដែលសុទ្ធសឹងជាការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធជនបទដែរ។

២៥-**ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ៖** ក្នុងគោលបំណងលើកកម្ពស់គុណភាពនៃការរៀបចំផែនការលទ្ធកម្ម និងអនុលោមភាពនៃការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំ ដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំកាន់តែមានប្រសិទ្ធភាព **ហើយជាពិសេសធានាឱ្យថវិកាអាចអនុវត្តបានភ្លាមចាប់ពីខែមករានៃឆ្នាំសារពើពន្ធ** គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់

មុខចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូច្នេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើគម្រោងថវិកាឆ្នាំ ២០២២ របស់ខ្លួនចំនួនពីរច្បាប់ (០១ ច្បាប់បញ្ជូនទៅអគ្គនាយកដ្ឋានថវិកា និង ០១ ច្បាប់ទៀត បញ្ជូនទៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) សម្រាប់ការប្រជុំពិភាក្សាកម្រិតបច្ចេកទេស និងការចរចាកញ្ចប់ថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង។ គោលការណ៍និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្ម ត្រូវអនុលោមតាមបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

បន្ទាប់មក ផ្អែកលើស្មារតី និងលទ្ធផលនៃការចរចាកញ្ចប់ថវិកា ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវកែសម្រួលសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំឱ្យមានសង្គតិភាពជាមួយនឹងកញ្ចប់ថវិកាដែលទទួលបាននៅក្នុងកិច្ចប្រជុំចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង រួចបញ្ជូនសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានកែសម្រួលរួចនេះ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **យ៉ាងយូរបំផុតត្រឹមសប្តាហ៍ទី ៣ ខែ វិច្ឆិកា** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

២៦-**ការរៀបចំផែនការឥណទានរដ្ឋទេយ្យបុរេប្រទាន** ត្រូវធ្វើឡើងដំណាលគ្នានឹងការរៀបចំគម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ សម្រាប់ពិនិត្យ និងពិភាក្សាក្នុងកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ។ ក្នុងអំឡុងពេលប្រជុំការពារគម្រោងថវិកា មិនតម្រូវឱ្យពិនិត្យមើលលម្អិតលើតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានទេ ប៉ុន្តែក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលរាជធានី-ខេត្ត (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល) ត្រូវធានាថាឥណទានថវិកាដែលត្រូវយកមករៀបចំតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន មិនត្រូវត្រួតគ្នានឹងឥណទានថវិកាដែលត្រូវបានគ្រោងទុកអនុវត្តកិច្ចលទ្ធកម្មសាធារណៈ តាមនីតិវិធីទូទាត់ត្រង់ និងនីតិវិធីចំណាយផ្សេងទៀតទេ។

២៧-ដោយឡែក**ចំណាយមូលធន/វិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ (ជំពូក ២១) និងចំណាយជួសជុល ស្តារ និងថែទាំផ្លូវថ្នល់ និងធារាសាស្ត្រ (ជំពូក ៦១)** ត្រូវបន្តអនុវត្តតាមនីតិវិធីដែលបាន**និងកំពុងអនុវត្ត**ជាធរមាន។

២៨-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលអនុវត្តថវិកាកម្មវិធី ត្រូវតែផ្តល់របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ ២០២០ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត ហើយក៏ជាកម្មវត្ថុសម្រាប់ការលើកទឹកចិត្ត ឬការកាត់បន្ថយគម្រោងចំណាយឆ្នាំ ២០២២ ផងដែរ។ *នៅពេលពិភាក្សា និងចរចាថវិកា ក្រសួង-ស្ថាប័ននីមួយៗត្រូវតែរៀបចំជាបទបង្ហាញអំពីរបាយការណ៍សមិទ្ធកម្មឆ្នាំ ២០២០ របាយការណ៍សមិទ្ធកម្មពាក់កណ្តាលឆ្នាំ ២០២១ និងការគ្រោងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំ ២០២២។*

២៩-ទន្ទឹមនេះ ផ្អែកលើមូលដ្ឋាននៃច្បាប់ថវិកាឆ្នាំ ២០២១ ដែលកំពុងអនុវត្ត, ក្នុងការរៀបចំថវិកាឆ្នាំ ២០២២ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោម-ជាតិពាក់ព័ន្ធ អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀតផ្ទៃក្នុង ឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានការប្រែប្រួល,

- ការផ្ទេរឥណទានថវិកាបន្ថែម សម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

៣០-ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ននីមួយៗ។

## ៣.៣- កាលវិភាគនៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២២

៣១-រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២។ នៅក្នុងកិច្ចដំណើរការនេះ ចាប់ពីសប្តាហ៍ទី ២ នៃខែ កក្កដា រហូតដល់ដំណាច់ខែ កញ្ញា ឆ្នាំ ២០២១ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមពិភាក្សា និងចរចាគម្រោងថវិកាជាមួយក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីធ្វើការបូកសរុបគម្រោងចំណូល-ចំណាយរៀបចំជាសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់**ការគ្រប់គ្រងឆ្នាំ ២០២២ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ដាក់ជូនគណៈរដ្ឋមន្ត្រី នៅក្នុងសប្តាហ៍ទី ១ នៃខែ តុលា ឆ្នាំ ២០២១ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយដាក់ជូនរដ្ឋសភាឱ្យបានមុនសប្តាហ៍ទី ១ នៃខែ វិច្ឆិកា ឆ្នាំ ២០២១ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះ ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២១។**

៣២-ឯកសារផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ និងគម្រោងចំណូល-ចំណាយថវិកាឆ្នាំ ២០២២ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បានដាក់ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានសម្រាប់ការចរចាថវិកាទាំងកម្រិតបច្ចេកទេស និងការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង ដើម្បីធ្វើយុត្តិកម្មកញ្ចប់ថវិការបស់ខ្លួន។ ការចរចាថវិកាកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនេះ នឹងត្រូវពិភាក្សាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) និងតាមចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) លើមូលដ្ឋាននៃគោលការណ៍ និងវិធានការនៃការគ្រោងថវិកាដូចបានលម្អិតខាងលើ ដើម្បី

ជានាប្រសិទ្ធភាពនៃការវិភាជថវិកា ក្នុងកម្រិតនៃពិតានកញ្ចប់ថវិកាឆ្នាំ ២០២២ ដែលបានកំណត់ និងក្នុងកម្រិតលទ្ធភាពថវិកាជាតិទ្រទ្រង់បាន។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធណាមួយមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ទៅតាមគោលការណ៍ និងតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃកម្រិតពិតានចំណាយគោល ដោយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូកខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ឱ្យបានទាន់ពេលវេលា និងគ្រប់ជ្រុងជ្រោយ។ តួលេខគម្រោងចំណូល-ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ ( ១, ២, ៣.. ) ហើយឯកតាទាបបំផុតគិតត្រឹម ០,១ លានរៀល។

## ៤- សេចក្តីសន្និដ្ឋាន

៣៣-ខ្លឹមសារនៃសារាចរណែនាំនេះ បានកំណត់ក្របខ័ណ្ឌ និងវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋានដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ រៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន សំដៅជានាសម្រេចឱ្យបានជោគជ័យនូវគោលបំណងគោលនយោបាយ និងកម្មវិធីដើម្បីរួមចំណែកសម្រេចឱ្យបានគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ ក្នុងបរិការណ៍នៃការបន្សាំទៅនឹងផលវិបាកនៃជំងឺកូវីដ-១៩ និងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងវិធានការចាំបាច់ និងបន្ទាន់នានា ក្នុងគោលបំណងដើម្បីរក្សាលំនឹងសេដ្ឋកិច្ច តាមរយៈការបន្តការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ការបន្តរក្សាលំនឹងសកម្មភាពអាជីវកម្ម, ការបន្តរក្សាលំនឹងជីវភាពប្រជាជន, ព្រមទាំងដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច តាមរយៈការបន្តបង្កើនភាពប្រកួតប្រជែង, ការបន្តជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបន្តកែទម្រង់រចនាសម្ព័ន្ធ។

៣៤-ទោះជាយ៉ាងណាក្តី ដើម្បីឱ្យគោលដៅទាំងឡាយដែលបានដាក់ចេញក្នុងសារាចរនេះ អាចអនុវត្តសម្រេចបានជោគជ័យ ថ្នាក់ដឹកនាំគ្រប់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ចាំបាច់ត្រូវខិតខំថែមទៀតប្រកបដោយឆន្ទៈប្តូរប្តេជ្ញ ជាពិសេសត្រូវតែផ្លាស់ប្តូរឥរិយាបទនិងផ្នត់គំនិតក្នុងការរៀបចំថវិកា ដោយខិតខំគោរពឱ្យបានខ្ជាប់ខ្ជួនតាមក្របខ័ណ្ឌ និងបណ្តាវិធានការ ព្រមទាំងគោលការណ៍ និងបច្ចេកទេសទាំងឡាយ ទាំងផ្នែកចំណូល និងផ្នែកចំណាយ ដែលកំណត់ដោយសារាចរណែនាំនេះ។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីមិនត្រឹមតែអាចបង្កើនសក្តានុពលនៃតួនាទីរបស់ថវិកា ឱ្យទៅជាឧបករណ៍សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងអាចធ្វើជាចន្ទល់ដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដ្ឋានកម្មវិធីកែទម្រង់ដទៃទៀត ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋផងដែរ។

៣៥-ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល-ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២២ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) **ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០២១** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាថវិកាកម្រិតបច្ចេកទេស និងបូកសរុប ហើយអាចចាប់ផ្តើមដំណើរការចរចាថវិកាកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័នទាន់ពេលវេលាកំណត់។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា)។

ថ្ងៃ អង្គារ ១៣ រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង
"ដើម្បីមុខការ "
-ឯកសារ-កាលប្បវត្តិ